# ទិសដៅជាយុទ្ធសាស្ត្រ និង ការវិនិយោគជាអាទិភាពរបស់ CEPF នៅតំបន់ឥណ្ឌូចិន

| ទិសដៅយុទ្ធសាស្ត្ររបស់ CEPF | ការវិនិយោគជាអាទិភាពរបស់ CEPF |
|---|---|
| **១. ការការពារជាអាទិភាពដល់ប្រភេទដែលទទួលរងការគំរាមកំហែងក៏រិតពិភពលោកនៅឥណ្ឌូចិនដោយកាត់បន្ថយការគំរាមកំហែងចំបង។** | ១.១ កំណត់ និង សង្គ្រោះដល់ពពួកសត្វសំខាន់ៗដែលទទួលរងការគំរាមកំហែងក្នុងពិភពលោកចំនួន ៦៧ប្រភេទពីការធ្វើអាជីវកម្មហួសក៏រិត និងជំនួញខុសច្បាប់ |
| | ១.២ អនុវត្តយុទ្ធនាការផ្សព្វផ្សាយលើកកំពស់ការយល់ដឹងជាសាធារណៈ ដើម្បីជួយពង្រឹងការអនុវត្តគោលនយោបាយដែលមានស្រាប់ស្តីពីអាជីវកម្មសត្វព្រៃ និងចូលរួមកាត់បន្ថយតំរូវការរបស់អ្នកប្រើប្រាស់លើពពួកសត្វដែលទទួលរងការគំរាមកំហែងក្នុងពិភពលោកទាំង ៦៧ ប្រភេទ និងផលិតផលទាំងឡាយដែលផលិតចេញពីពួកវា ។ |
| | ១.៣ សិក្សាស្រាវជ្រាវពីស្ថានភាព និងរបាយនៃពពួករុក្ខជាតិដែលទទួលរងការគំរាមកំហែងក្នុងពិភពលោក ហើយលទ្ធផលដែលរកឃើញត្រូវបានយកទៅធ្វើផែនការ គ្រប់គ្រង និងបង្កើនការយល់ដឹង ។ |
| | ១.៤ សិក្សាវាយតម្លៃពីស្ថានភាពគំរាមកំហែងក៏រិតពិភពលោកនៃចំណាត់ថ្នាក់ប្រភេទទឹកសាបដែលបានជ្រើសរើស និងបញ្ចូលលទ្ធផលដែលរកឃើញទៅក្នុងដំណើរការរៀបចំផែនការសំរាប់ការអភិរក្សនៃជីវៈចំរុះតំបន់ដីសើម និងទៅក្នុងផែនការអភិវឌ្ឍន៏ក្នុងទន្លេមេគង្គ និងដៃសំខាន់ៗរបស់វា ។ |
| | ១.៥ ធ្វើការស្រាវជ្រាវលើពពួកសត្វស្លាប ១២ ប្រភេទ ដើម្បីធ្វើបច្ចុប្បន្នភាពនូវពត៌មានស្តីពីស្ថានភាព និងរបាយរបស់ពួកវា ។ |
| | ១.៦ បោះពុម្ពឯកសារស្តីពីពពួកសត្វដែលទទួលរងការគំរាមកំហែងក្នុងពិភពលោកជាភាសាជាតិ ។ |
| **២. បង្កើតជាវិធីសាស្ត្រថ្មីដែលដឹក** | ២.១ បង្កើតវិធីសាស្ត្រគ្រប់គ្រងការអភិរក្សតាមរបៀបថ្មីមួយដោយមានការចូលរួមពីអ្នកពាក់ពន្ធ័ និងការផ្តួចផ្តើមការពារក្នុងតំបន់ជីវចំរុះសំខាន់ៗទាំង ២៨កន្លែង |

| | |
|---|---|
| **នាំដោយសហគមន៍មូលដ្ឋានក្នុងការអភិរក្សដោយផ្អែកលើទីតាំងនៅតំបន់ជីវចំរុះសំខាន់ៗទាំង២៨កន្លែង** | ២.២ បង្កើតនូវស្តង់ដារ និងកម្មវិធីជាលក្ខណៈតំបន់ដែលទប់ស្កាត់នូវរាល់ការធ្វើអាជីវកម្មហួសកំរិតលើជីវៈចំរុះ និងអនុវត្តកម្មវិធីសាកល្បងនៅតំបន់ដែលបានជ្រើសរើស ។ |

| | |
|---|---|
| **៣. ធ្វើឱ្យអ្នកពាក់ព័ន្ធ សំខាន់ៗចូលរួមក្នុងការសំរបសំរួលការងារអភិរក្សជីវៈចំរុះ និងគោលដៅអភិវឌ្ឍន៍ដោយផ្តោតសំខាន់លើតំបន់ភ្នំខ្ពង់រាបភាគខាងជើង និងទន្លេមេគង្គព្រមទាំងដៃសំខាន់ៗរបស់វា** | ៣.១ គាំទ្រដល់ការខំប្រឹងប្រែងរបស់សង្គមស៊ីវិលក្នុងការវិភាគនូវកម្មវិធី ផែនការ និងគោលនយោបាយអភិវឌ្ឍន៍នានា ដោយវាយតំលៃពីផលប៉ះពាល់លើជីវចំរុះ និងប្រព័ន្ធអេកូស៊ីស្ទែម ព្រមទាំងស្នើឡើងនូវជំរើសផែនការអភិវឌ្ឍន៍ថ្មី និងវិធានការសមស្របផ្សេងៗទៀតដើម្បីកាត់បន្ថយផលប៉ះពាល់នោះ ។ |
| | ៣.២ គាំទ្រដល់ការផ្តួចផ្តើមដែលបង្កើនការគាំទ្រដល់ការអភិរក្សជីវៈចំរុះចេញពីគំរោង និងកម្មវិធីអភិវឌ្ឍន៍ |
| | ៣.៣ បង្កើនការយល់ដឹងដល់អ្នកធ្វើការសំរេចចិត្ត អ្នកសារពត៌មាន និងអ្នកច្បាប់ |
| **៤. ផ្តល់ភាពដឹកនាំជាយុទ្ធសាស្ត្រ និងការសំរបសំរួលការវិនិយោគរបស់ CEPF ប្រកបដោយប្រសិទ្ធិភាពតាមរយៈក្រុមការងារប្រចាំតំបន់** | ៤.១ កសាងក្រុមការងារសង្គមស៊ីវិលដើម្បីធ្វើការទំនាក់ទំនងឆ្លងស្ថាប័ន និងនយោបាយ ឆ្ពោះទៅរកការសំរេចឱ្យបាននូវទិសដៅរួមនៃការអភិរក្ស ដូចដែលបានរៀបរាប់នៅក្នុងឯកសារប្រព័ន្ធអេកូស៊ីស្ទែមនេះ ។ |